# កិច្ចព្រមព្រៀងរវាងក្រុមហ៊ុនញូអេធីធីស៊ូម៉េកឃីង(ខេមបូឌា)ឯ.ក

# ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និង ប្រធានក្រុមប្រចាំក្រុមហ៊ុន

នៅថ្ងៃទី០៣ ខែ សីហាឆ្នាំ២០២៣ វេលាម៉ោង ០៩និង០០នាទីនៅក្នុងក្រុមហ៊ុនញូអេធីធី ស៊ូម៉េកឃីង(ខេមបូឌា)ឯ.ក

មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និង តំណាងកម្មករ និយោជិត

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករ និយោជិតទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ននៃក្រុមហ៊ុនដែលខ្វះការបញ្ជាទិញដែលបណ្តាលអោយសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ។ហេតុនេះក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន១២៥នាក់(ស្រី៩៣នាក់) ក្នុងចំណោមកម្មករនិយោជិតសរុប ២១៨៧នាក់(ស្រី១៦៦៩)នាក់។

រយៈពេល ៣២ថ្ងៃ ដោយគិតពីថ្ងៃទី១៤ ខែ សីហា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣។

ហើយកំឡុងពេលព្យួរកិច្ចសន្យាការងារកម្មករនិយោជិតបានឯកភាពទទួលនូវប្រាក់ឧបត្ថម្ភដែលផ្តល់ជូនដោយរោងចក្រដូចខាងក្រោម៖

- ចំនួន ៣០ដុល្លារអាម៉េរិក សំរាប់រយៈពេល ១៨ថ្ងៃដោយគិតពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣។
- ចំនួន ១៥ដុល្លារអាម៉េរិក សំរាប់រយៈពេល ១៤ថ្ងៃដោយគិតពីថ្ងៃទី០១ ខែ កញ្ញាឆ្នាំ២០២៣ដល់ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣។ ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះនឹងបើកជូនបងប្អូនកម្មករនិយោជិតនៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០២៣។

អង្គប្រជុំបានចប់នៅវេលាម៉ោង១១នឹង០០នាទីព្រឹកនាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយនឹងស្និទស្នាល ក្រោមស្មារតីទទួលខុសត្រូវខ្ពស់ នឹងយោគយល់គ្នាទៅវិញទៅមក។ដើម្បីបញ្ជាក់ក្នុងកិច្ចព្រមព្រៀងនេះគ្រប់ភាគីទាំងអស់បានចុះហត្ថលេខាឬផ្តិតមេដៃទុកជាភស្តុតាងស្រាប់។

ថ្ងៃព្រហស្បតិ៍២រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

កំពង់ស្ពឺថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣

ហត្ថលេខានិងត្រា

តំណាងក្រុមហ៊ុន

ស្នាមមេដៃប្រតិភូបុគ្គលិក

ជី សាក់ឡា | សាត សុខនីម | សាំង សុខចាន់

| | | |
|---|---|---|
| អុន សីហា | សៀន ណាំមួយ | ឃីម ឃីម |
| ហ៊ិន តយ | មីន សុខនាង | ឆាំ សុគា |
| សុខ ស្រីណេ | សុខ ឡី | ជឹម រ៉េន |
| ភាស់ ស្រីមួយ | ស៊ីម ម៉ៅ | ប៊ុត សោភ័ណ្ឌ |
| ទុយ ស្រីនីន | ឈុំ ផល្លី | សុត ស្រីមួយ |
| ថន យ៉ានី | អ៊ុត ឡាង | អ៊ុត រី |
| យៀង សំនៀង | ធី ដាឡែន | ភឿន ស្រីល័ក្ខ |



យន សុឃី